# មេរៀនទី១១៦៖ សាខេឡើងដើមឈើដើម្បីមើលព្រះយេស៊ូវ

លូកា ១៩៖១-១០

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/atLjfnkxVRo

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/mIFCLSU9Me4

**គោលបំណង៖** ព្រះយេស៊ូវផ្លាស់ប្តូរការរស់នៅរបស់យើង។

**Memory Verse:** “For the Son of Man came to seek and to save the lost.” (Luke 19:10)
**ខគម្ពីរចងចាំ៖** លូកា១៩៖១០ *“ដ្បិតកូនមនុស្សបានមកដើម្បីនឹងរក ហើយជួយសង្គ្រោះដល់មនុស្សបាត់បង់។”*

**ចំរៀង** ( *យូធូបលីង* )៖
១.ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/aasilZXGorc
២. ទ្រង់យាងមកផ្តល់ជីវិត https://youtu.be/PXQCMUWh9RY
៣. ខ្ញុំដឹងខ្លួនហើយ https://youtu.be/cNotISrjHI0

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«លេងលោតកំពស់»**

សំភារៈដែលត្រូវការ៖ កៅស៊ូឬក៏ខ្សែ



១. ចែកកុមារជា២ក្រុម ហើយជ្រើសរើសកុមារពីរនាក់ ពីក្រុម នីមួយៗ។
២. ឲ្យកុមារពីរនាក់ដែលបានជ្រើសរើសនោះប៉ាវ ក្រុមណាដែលប៉ាវឈ្នះលេងមុន
៣. ក្រុមដែលប៉ាវចាញ់ត្រូវអង្គុយដោយកាន់កៅស៊ូឬខ្សែ នោះដោយដាក់កៅស៊ូនោះត្រឹមជង្គង់ ហើយក្រុមដែលឈ្នះ ត្រូវលោតរំលោងកៅស៊ូនោះ ដោយមិនឲ្យប៉ះកៅស៊ូនោះទេ



៤. ប្រសិនបើកុមារលោតមិនប៉ះកៅស៊ូទេនោះ នៅអ្នកកាន់កៅស៊ូត្រូវដាក់កឹតតែខ្ពស់ ( ត្រឹមចង្កេះ ត្រឹមស្មា ត្រឹមក ត្រឹមត្រចៀក ។ល។)។ ប្រសិនបើពួកគេលោតប៉ះកៅស៊ូនោះ នោះក្រុមគេនឹងចាញ់ល្បែងនេះ។
៥. បន្ទាប់មកគេត្រូវប្តូរគ្នាលេងវិញម្តង
៦. ក្រុមណាដែលអាចលោតរំលងកៅស៊ូបានកម្ពស់ខ្ពស់ ជាងគេក្រុមនោះនឹងឈ្នះល្បែងនេះ។
៧. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា បើទោះ បីជាយើងមានកម្ពស់ទាបមិនអាចលោតរំលងបានខ្ពស់ក៏ដោយ ប៉ុន្តែព្រះយេស៊ូវនៅតែស្រលាញ់ និងជួយពួកយើងជានិច្ច។

**៤. ការណែនាំមេរៀន**

តើប្អូនប៉ុន្មាននាក់ធ្លាប់លួចលុយម៉ាក់ឬអត់?តើប្អូនណាធ្លាប់លួចនំរបស់មិត្តនៅសាលា?តើប្អូនធ្លាប់លួចយកខ្មៅដៃមិត្តភក្តនៅសាលាឬអត់អូន?តើប្អូនខឹងនឹងមិត្តភក្តិរបស់ប្អូនដែរឬទេនៅពេលដែលគេលួចរបស់អ្វីមួយពីប្អូន? ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់ដែលមានចិត្តលោភលន់មកជាមានចិត្តសប្បុរស បន្ទាប់ពីគាត់បានជួបព្រះយេស៊ូវ!

### ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីររបស់យើងនៅថ្ងៃនេះនិយាយអំពីបុរសម្នាក់ដែលមានឈ្មោះថា សាខេ។ គាត់ជាមេលើពួកអ្នកយកពន្ធ ដែលមានន័យថាគាត់គឺជាជនជាតិយូដាដែលបានយកលុយពីជនជាតិយូដាផ្សេងទៀតសម្រាប់រដ្ឋាភិបាលរ៉ូម ហើយទុកលុយខ្លះសម្រាប់ខ្លួនគាត់។ ដើម្បីឲ្យគាត់ក្លាយជាអ្នកមាន គាត់ត្រូវប្រមូលពន្ធលើសពីអ្វីដែលរដ្ឋាភិបាលរ៉ូមកំណត់ឲ្យគាត់ទារពីប្រជាជន ដូច្នេះគាត់អាចទុកលុយបន្ថែមទៀតសម្រាប់ខ្លួនគាត់។ នេះជារបៀបដែលធ្វើឲ្យគាត់ក្លាយជាអ្នកមាន។ ទោះបីគាត់ជាអ្នកមានក៏ដោយតែមនុស្សជាច្រើនបានស្អប់គាត់។

ថ្ងៃមួយ សាខេបានឮថាព្រះយេស៊ូវបានយាងមកក្រុងរបស់គាត់។ គាត់ចង់ឃើញព្រះយេស៊ូវ ប៉ុន្តែគាត់មានការព្រួយបារម្ភថា មនុស្សខ្ពស់នឹងបាំងគាត់មិនអាចមើលឃើញព្រះយេស៊ូវ។ សាខេគឺជាបុរស ដែលមានមាឌតូចទាបម្នាក់ប៉ុណ្ណោះ។ សាខេបានសម្រេចចិត្តឡើងលើដើមឧទុម្ពរ ដូច្នេះគាត់អាចមើលឃើញព្រះយេស៊ូវបានយ៉ាងច្បាស់។

ព្រះយេស៊ូវដឹងថា សាខេនៅលើដើមឈើ។ ទ្រង់ដឹងថា ដួងចិត្តរបស់សាខេគឺក្រៀមក្រំនិងពិបាកចិត្ត។ ព្រះយេស៊ូវដឹងថាសាខេលោភលន់ និងចង់បានលុយរបស់ប្រជាជន។ ប៉ុន្តែព្រះយេស៊ូវបានមើលទៅសាខេ និងញញឹមដាក់គាត់!ព្រះយេស៊ូវបានមានបន្ទូលថាទ្រង់នឹងទៅស្នាក់នៅផ្ទះរបស់សាខេ។ មនុស្សជាច្រើនមាន ការភ្ញាក់ផ្អើលជាខ្លាំង ពីព្រោះព្រះយេស៊ូវចង់ហូបអាហារនៅផ្ទះរបស់មនុស្ស ដែលពោរពេញទៅដោយអំពើបាបនិងជាម្នាក់ដែលពួកគេស្អប់ផងដែរ។ មនុស្សម្នាគិតថា ពួកគេគឺប្រសើរជាងសាខេ ប៉ុន្តែនៅក្នុងព្រះនេត្ររបស់ព្រះយេស៊ូវ ពួកគេគ្រប់គ្នាគឺត្រូវការព្រះយេស៊ូវ។ កំឡុងពេលដែលសាខេនៅជាមួយព្រះយេស៊ូវ ទ្រង់ក៏បានផ្លាស់ប្តូរចិត្តគំនិតរបស់សាខេ។ សាខេមានអារម្មណ៍ថាខុសឆ្គងជាខ្លាំងដែល គាត់បានយកប្រាក់ពីប្រជាជនទាំងអស់នោះ។ គាត់ចង់ឲ្យប្រាក់ដែលនៅសល់ទាំងអស់នោះត្រឡប់ទៅពួកគេវិញ។ ការជួបព្រះយេស៊ូវបានធ្វើឲ្យសាខេផ្លាស់ប្តូរ!

ព្រះយេស៊ូវអាចធ្វើឲ្យមនុស្សលោភ ទៅជាមានចិត្តសប្បុរសបាន និងមនុស្សដែលមិនល្អទៅជាល្អបាន។ ព្រះយេស៊ូវបានផ្លាស់ប្តូរការរស់នៅរបស់ពួកយើង ពីព្រោះទ្រង់ជាព្រះរាជបុត្រានៃព្រះ ហើយទ្រង់ស្រលាញ់ពួកយើង។ នៅពេលដែលយើងដឹងថា ព្រះយេស៊ូវស្រលាញ់យើងប៉ុនណានោះ យើងក៏ចង់ផ្លាស់ប្តូរដោយការស្រលាញ់អ្នកផ្សេងទៀតផងដែរ!

### ៦. សំនួរពិភាក្សា

១.តើសាខេធ្វើអ្វី ក្នុងនាមជាមេលើពួកអ្នកយកពន្ធនោះ? *(ព្រោះគាត់ជាជនជាតិយូដា គាត់ជាអ្នកប្រមូលពន្ធពីជនជាតិយូដាផ្សេងទៀត ដើម្បីឲ្យទៅរដ្ឋាភិបាលរ៉ូម ប៉ុន្តែគាត់ក៏បានទុកលុយខ្លះសម្រាប់ខ្លួនគាត់ផងដែរ)*

២. ដោយព្រោះតែគាត់ទាប តើសាខេបានធ្វើដូចម្តេច ដើម្បីឲ្យគាត់អាចមើលឃើញព្រះយេស៊ូវបាន?
*(គាត់បានឡើងដើមឈើ)*

៣. តើព្រះយេស៊ូវបានធ្វើដូចម្តេចនៅពេលដែលទ្រង់បានជួបសាខេ?
*(ទ្រង់បានប្រាប់ថាទៅញ៉ាំអាហារនៅផ្ទះសាខេ)*

៤. តើសាខេបានផ្លាស់ប្តូរអ្វីខ្លះបន្ទាប់ពីគាត់បានជួបព្រះយេស៊ូវ?
*(គាត់ចង់ឲ្យប្រាក់ទាំងអស់ដែលគាត់មានទៅប្រជាជនវិញ)*

៥.តើអ្នកចង់ឲ្យព្រះយេស៊ូវផ្លាស់ប្តូរផ្នែកណាខ្លះនៅក្នុងជីវិតរបស់អ្នក? *(ចិត្តសប្បុរសជាងមុន, អត់ធ្មត់ជាងមុន, ល្អជាងមុន ។ល។)*

### ៧. ល្បែងកំសាន្ត «វាយពងទា»

សម្ភារៈដែលត្រូវការ៖ ពងទា(អាចប្រើក្រូចឆ្មារជំនួសក៏បាន) ដបទឹក ស្កុត ក្រមា តុ ម្សៅ



១. ឲ្យកុមារទាំងអស់ឈរជាជួរ

២. បន្ទាប់ពីចងក្រមាបិតមុខកុមាររួច គ្រូត្រូវយកស្កុតមកបិតពងទា ឲ្យជាប់ជាមួយតុ។ កុមារដែលបានបិតភ្នែករួចនោះ

ចាញ់



ត្រូវប្រើដកទឹកទទេមកវាយពង ទាដែលបានបិតនៅលើតុនោះ
៣. កុមារម្នាក់មានសិទ្ធិវាយពងទានោះបានតែម្ដងប៉ុណ្ណោះ។
៤. គ្រូត្រូវបិតពងទានៅកន្លែងខុសៗគ្នានៅលើតុ សម្រាប់កុមារនីមួយៗ
៥. ប្រសិនបើកុមារមិនអាចវាយពងទាបានទេនោះគ្រូនឹងយកម្សៅលាប មុខរបស់ពួកគេ។
៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះយេស៊ូវចង់ផ្លាស់ប្ដូរពួកយើង ដូច្នេះយើងនឹងមានជីវិតល្អប្រសើរ ដូចជារបៀបដែលគ្រូបានផ្លាស់ប្ដូរទីតាំងរបស់ពងទាអីចឹងដែរ។

**៨. ខគម្ពីរចងចាំ**

**លូកា ១៩៖១០** *“ដ្បិតកូនមនុស្សបានមក ដើម្បីនឹងរក ហើយជួយសង្គ្រោះដល់ មនុស្សបាត់បង់។”*

**៩. ហត្ថកម្ម “សាខេឡើងដើមឈើដើម្បីមើលព្រះយេស៊ូវ”**

សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម ក្រដាសពណ៌បៃតង កន្ត្រៃ ការបិត និងកូល័រ












១. ឲ្យក្រដាសហត្ថកម្មទៅកុមារគ្រប់ៗគ្នា
២. ឲ្យពួកគេផាត់ពណ៌រូបដើមឈើ រូបសាខេ និងរូបព្រះយេស៊ូវ។
៣. ឲ្យកុមារកាត់ប្រអប់រូបដើមឈើ រូបសាខេ និងរូបព្រះយេស៊ូវចេញមក។
៤. កាត់ក្រដាសពណ៌បៃតងតាមទទឹងវែងៗ ហើយបិតវាជារង្វង់។ បន្ទាប់មកបិតវាភ្ជាប់ជាមួយដើមឈើ។ ធ្វើបែបនេះរហូតដល់ មើលទៅដើមឈើស្រស់ស្អាតហើយ។
៥. បន្ទាប់មកបិតរូបរបស់លោកសាខេភ្ជាប់ជាមួយស្លឹកឈើពណ៌បៃតង។
៦. បិតរូបរបស់ព្រះយេស៊ូវនៅជិតដើមឈើនោះ។
៧. ឲ្យកុមារអាន និងចងចាំខគម្ពីរនេះ។

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ព្រះយេស៊ូវមិនបានបង្ខំនរណាម្នាក់ឲ្យដើរតាមទ្រង់នោះទេ។ ព្រះអង្គចង់ឲ្យយើងចេះ ស្រលាញ់ដូចទ្រង់បានស្រលាញ់យើងដែរ។ ព្រះយេស៊ូវបានបំភាន់មនុស្ស «ស្អាត»និង«សុចរិត»ម្ដងហើយម្ដងទៀត ដោយ ទទួលយកការជូនដំណឹងពិសេសអំពី«មនុស្សមានបាប»ដូចជាសាខេ។ ពួកយើងបានច្រៀងចម្រៀង អំពីសាខេ «ជាមនុស្សទាបម្នាក់» ប៉ុន្តែការពិតគឺថាគាត់ប្រហែលជាបានកាន់អំណាចដ៏អស្ចារ្យលើអ្នក ផ្សេងទៀតក្នុងឋានៈ ជាមេលើអ្នកយកពន្ធ។ តែគាត់ក៏ «មិនស្អាត»ដែរ បើប្រៀបជាមួយពួករ៉ូមនោះ។ក៏ប៉ុន្តែ ព្រះយេស៊ូវហ៊ានបរិភោគជាមួយសាខេ ដែលមិនស្អាត ហើយប្រកាស ថា អ្នកទារពន្ធដែលគ្រប់គ្នាស្អប់នោះក៏ជា«កូនរបស់អ័ប្រាហាំ»ដែរ។ តើនេះប្រាប់យើងអ្វីខ្លះអំពីព្រះ? ទ្រង់ស្រឡាញ់ ហើយតែងតែប្រាថ្នានាំមនុស្សមានបាបឲ្យមានជំនឿលើទ្រង់។ ប្រហែលជាដំណើររឿងរបស់ព្រះយេស៊ូវ និងសាខេនេះ អាចផ្ដល់ឱ្យយើងនូវហេតុផលដើម្បីគិតម្ដងទៀតនៅពេលក្រោយ ដែលយើងហ៊ានគិតថាខ្លួនឯងប្រសើរជាងឬ "ស្អាតជាង" នរណាម្នាក់ផ្សេងទៀតនោះ។

# សាខេឡើងដើមឈើដើម្បីមើលព្រះយេស៊ូវ



លូកា ១៩៖១០ *“ដ្បិតកូនមនុស្សបានមកដើម្បីនឹងរក ហើយជួយសង្គ្រោះដល់មនុស្សបាត់បង់។”*





